ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**

-សំណុំរឿងព្រហ្មទណ្ឌលេខៈ ៥៨២

ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២១

-សំណុំរឿងជំនុំជម្រះលេខៈ ៨៨

ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២

-សាលក្រមព្រហ្មទណ្ឌលេខៈ ៤៧(ត)

ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តតាកែវ

បានបើកសវនាការជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២។

ប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃពុធ ១៣កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ ដោយមានសមាសភាពដូចតទៅ៖

**សមាសភាពជំនុំជម្រះ**

-លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងខេត្តតាកែវ

-លោក [redacted] ជាចៅក្រមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងខេត្តតាកែវ

-លោក [redacted] ជាចៅក្រមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងខេត្តតាកែវ

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តតាកែវ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៥៨២ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២១ ដែលមានដូចខាងក្រោម៖

**ជនជាប់ចោទ**

-ឈ្មោះ [redacted] ទូច ហៅ ជីវ័ន្ត ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] ផ្លែង (ស្លាប់) ម្តាយឈ្មោះ [redacted] ឈាងប៊ុន (រស់) ប្រពន្ធឈ្មោះ [redacted] ស្រីមុំ មានកូនចំនួន ០៣នាក់ ជានីតិជន ទោសពីមុន-គ្មាន។ (ឃុំខ្លួនថ្ងៃទី២៦-០៩-២០២១)

ជាប់ចោទពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិក្រាំងព្រាល់ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

## អំពីអង្គហេតុ

កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង១១ និង៣០នាទី កម្លាំងសមត្ថកិច្ចនៃការិយាល័យប្រឆាំងបទល្មើសគ្រឿងញៀននៃមន្ទីរប្រឆាំងគ្រឿងញៀន បានសហការជាមួយសមត្ថកិច្ចនគរបាលនៃស្នងការដ្ឋាននគរបាលខេត្តតាកែវ បានចុះប្រតិបត្តិការបង្ក្រាបករណី ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចភូមិក្រាំងក្បាល់ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ ដោយបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ខួច ហៅ ជីវ័ន្ត ភេទប្រុស អាយុ៤៧ឆ្នាំ និងដកហូតបានថ្នាំញៀនប្រភេទមេតំហ្វេតាមីនអាយ (ម៉ាទឹកកក) ទម្ងន់ ៨៥៤,៣៦ក្រាម និងទូរស័ព្ទចំនួន០១គ្រឿង។ ក្នុងការសាកសួរជនជាប់ចោទខាងលើបានឆ្លើយថា ចំពោះថ្នាំញៀនដែលសមត្ថកិច្ចដកហូតបានខាងលើ គឺខ្លួនយកពីឈ្មោះ តោ ភេទប្រុស អាយុ២៨ឆ្នាំ ប្រើលេខទូរស័ព្ទ ០៨៨ ៩២ ២៩ ៧៧៧ ហើយសមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមកតុលាការដើម្បីចាត់ការតាមនីតិវិធី។

បានឃើញៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខៈ ៤២៨ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តតាកែវ លើឈ្មោះ [redacted] ខួច ហៅ ជីវ័ន្ត។

បានឃើញៈដីកាសម្រេចឱ្យឃុំខ្លួនជាបណ្តោះអាសន្នលេខៈ ៤៣៨ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ លើឈ្មោះ [redacted] ខួច ហៅ ជីវ័ន្ត។

បានឃើញៈដីកាបង្គាប់ឱ្យឃុំខ្លួនជាបណ្តោះអាសន្នលេខៈ ៤៤៨ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ លើឈ្មោះ [redacted] ខួច ហៅ ជីវ័ន្ត។

បានឃើញៈដីកាសន្និដ្ឋានស្ថាពរលេខៈ ០៣៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ។

បានឃើញៈដីកាដំណោះស្រាយលេខៈ ៥៨ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ។

បានឃើញៈដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខៈ ៨៨ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តតាកែវ។

## នាពេលពិភាក្សាដេញដោល

-ជនជាប់ចោទឈ្មោះ [redacted] ខួច ហៅ ជីវ័ន្ត មានវត្តមាន។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មានវត្តមាន។

ជនជាប់ចោទឈ្មោះ [redacted] ខួច ហៅ ជីវ័ន្ត បានឆ្លើយថាៈ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង១២ថ្ងៃត្រង់ ខ្លួនបានទទួលយកថ្នាំញៀនពីគេនៅភ្នំពេញ តែខ្លួនមិនស្គាល់ឈ្មោះ និងអាសយដ្ឋាននោះទេ ដោយយកទៅឱ្យគេនៅចំណុចគីឡូម៉ែត្រលេខ៥១ ផ្លូវជាតិលេខ៣ ស្រុកបាទី ខេត្តតាកែវ។ ចំពោះថ្នាំញៀនដែលខ្លួនបានស៊ីឈ្នួលដឹកឱ្យគេនោះ គឺមានចំនួន៩០ (កៅសិប)ក្រាម ដោយគេឱ្យឈ្នួលខ្លួនចំនួន ២០០.០០០ (ម្ភៃម៉ឺន)រៀល។ ចំពោះថ្នាំញៀនខាងលើ គឺឈ្មោះ តោ ភេទប្រុស អាយុ២៨ឆ្នាំ ជាអ្នកប្រើកូនចៅរបស់គេយកមកឱ្យខ្លួន ដើម្បីយកទៅឱ្យគេបន្ត ដោយប្រើលេខទូរស័ព្ទ ០៨៨ ៩២ ២៩



Scanned with CamScanner

៧៧៧។ នៅថ្ងៃកើតហេតុសមត្ថកិច្ចបានដកហូតទូរស័ព្ទចំនួន០១គ្រឿង និងថ្នាំញៀនចំនួន ៩០ (កៅសិប)ក្រាម។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនរយៈពេល០១ឆ្នាំមកហើយ តែមិនដែលជួញដូរនោះទេ។ ក្នុងរឿងនេះ ខ្លួនសុំសំណូមពរដល់ចៅក្រមមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន៖** ឆ្លងតាមការសួរដេញដោលនាពេលសវនាការ ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងពិនិត្យមើលរង្គហេតុ ឃើញថាមានលក្ខណៈស៊ីសង្វាក់ខ្ជាប់ញាក់បានថាជនជាប់ចោទឈ្មោះ [redacted] ខុច ហៅ ជីវ័ន្ត ពិតជាបានប្រព្រឹត្តអំពើ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិក្រាំស្បាល់ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ដូច្នេះតំណាងអយ្យការប្តឹងសុំឱ្យចៅក្រមជំនុំជម្រះពិនិត្យ និងសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន៖ ក្រោយពីចប់កិច្ចពិភាក្សាដេញដោលនាពេលសវនាការឃើញថា៖ កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ខុច គ្មានចេតនាជួញដូរសារធាតុញៀនទេ គាត់គ្រាន់តែជាអ្នកដឹកជញ្ជូនស៊ីឈ្នួលយកកម្រៃសេវាថ្លៃដឹកជញ្ជូន ដោយសារគាត់គឺជាអ្នករត់ម៉ូតូកង់បី និងមិនដឹងថាក្នុងស្បោងខ្មៅនោះមានគ្រឿងញៀនទេ ហើយកូនក្តីខ្ញុំបាទមានគ្រួសារនៅក្នុងបន្ទុកត្រូវចិញ្ចឹមបីបាច់ និងមានម្តាយចាស់ជរា និងមានកូនតូចៗចំនួន៣នាក់ ក្នុងបន្ទុកគ្រួសារត្រូវមើលថែទាំទៀតផង ជាពិសេសដើម្បីទុកឱកាសឱ្យកូនក្តីខ្ញុំបានកសាងជីវិតជាថ្មី និងបានដឹងពីកំហុសខុសឆ្គងនឹងច្បាប់រដ្ឋ។ ហេតុដូច្នេះ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ ស្នើរសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រាលទោសដល់កូនក្តីរបស់ខ្លួនផង។

-ក្រោយពីបានដំណើរការកិច្ចពិភាក្សាដេញដោលរួចរាល់ហើយ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបានពិនិត្យកំណត់ហេតុ ឯកសារវត្ថុតាង និងភស្តុតាង ។

-ក្រោយពីបានស្តាប់សំណូមពរសំដីចុងក្រោយរបស់ជនជាប់ចោទ។

-ក្រោយពីបានពិភាក្សាក្រុមប្រឹក្សាជំនុំជម្រះ។

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

-ក្រោយពីធ្វើការស៊ើបសួរតាមនីតិវិធីចប់សព្វគ្រប់ ចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ៥៨ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ ដោយបានបញ្ជូន៖ ឈ្មោះ [redacted] ខុច ហៅ ជីវ័ន្ត ភេទប្រុស អាយុ៤៧ឆ្នាំ (មានខ្លួន) មកជំនុំជម្រះពីបទៈ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិក្រាំស្បាល់ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ជនជាប់ចោទឈ្មោះ [redacted] ខុច ហៅ ជីវ័ន្ត បានឆ្លើយថា៖ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង១២ថ្ងៃត្រង់ ខ្លួនបានទទួលយកថ្នាំញៀនពីគេនៅភ្នំពេញ តែខ្លួនមិនស្គាល់ឈ្មោះ និងអាសយ

ដ្ឋាននោះទេ ដោយយកទៅឱ្យគេនៅចំណុចគីឡូម៉ែត្រលេខ៥១ ផ្លូវជាតិលេខ៣ ស្រុកបាទី ខេត្តតាកែវ។ ចំពោះថ្នាំញៀនដែលខ្លួនបានស៊ីឈ្នួលដឹកឱ្យគេនោះ គឺមានចំនួន៩០ (កៅសិប)ក្រាម ដោយគេឱ្យឈ្នួលខ្លួនចំនួន ២០០.០០០ (ម្ភៃម៉ឺន)រៀល។ ចំពោះថ្នាំញៀនខាងលើ គឺឈ្មោះ តោ ភេទប្រុស អាយុ២៨ឆ្នាំ ជាអ្នកប្រើកូនចៅរបស់គេយកមកឱ្យខ្លួន ដើម្បីយកទៅឱ្យគេបន្ត ដោយប្រើលេខទូរស័ព្ទ ០៨៨ ៩២ ២៩ ៧៧៧។ នៅថ្ងៃកើតហេតុសមត្ថកិច្ចបានដកហូតទូរស័ព្ទចំនួន០១គ្រឿង និងថ្នាំញៀនចំនួន ៩០ (កៅសិប)ក្រាម។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនរយៈពេល០១ឆ្នាំមកហើយ តែមិនដែលជួញដូរនោះទេ។ ក្នុងរឿងនេះខ្លួនសូមសំណូមពរដល់ចៅក្រមមេត្តាបន្ធូបន្ថយទោសដល់រូបខ្លួនផង។ គប្បីតុលាការពិចារណា។

-យោងតាមរបាយការណ៍លេខៈ ៥៨៤ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២១ របស់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន បានបញ្ជាក់ថា៖ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ ស្ថិតនៅភូមិត្រាំក្បាល ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ ពិតជាមានករណី ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] ខូច ប្រាកដមែន។

-ជនជាប់ចោទឈ្មោះ [redacted] ខូច ពិតជាមានចេតនាក្នុងការប្រព្រឹត្តអំពើ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលច្បាប់បានហាមឃាត់តាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-កំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀនលេខ ២០៦៨ គណហ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០២១ ជាលទ្ធផល បានបញ្ជាក់ថា វិជ្ជមាន សារធាតុញៀននៅក្នុងទឹកនោមរបស់ជនសង្ស័យឈ្មោះ [redacted] ខូច ពិតប្រាកដមែន គប្បីតុលាការពិចារណា។

-លទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ៣៤៥១៥/២២ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ លទ្ធផល៖ វិជ្ជមាន, វត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន, បរិមាណសារធាតុ មេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់គឺ ៧៧.៥៨%។

-នៅពេលឃាត់ខ្លួនសមត្ថកិច្ចបានដកហូតវត្ថុតាងពីឈ្មោះ [redacted] ខូច រួមមាន៖ ថ្នាំញៀនប្រភេទមេតំហ្វេតាមីន ពណ៌សថ្លា មានទម្ងន់ ៨៥៤.៣៦ ក្រាម និងទូរស័ព្ទពណ៌ប្រផេះ ចំនួន០១គ្រឿង ដោយមានការទទួលស្គាល់ពីសាមីខ្លួន តាមកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ គប្បីតុលាការពិចារណា។

-មានភស្តុតាង និងភ័ស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទ៖ ឈ្មោះ [redacted] ខូច ភេទប្រុស អាយុ៤៧ឆ្នាំ (ឃាត់ខ្លួន) មកជំនុំជម្រះពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិត្រាំក្បាល ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-ជនជាប់ចោទឈ្មោះ [redacted] ខូច គឺជានីតិជនមានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តតាមមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ។

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ខូច ធ្វើឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ របៀបរៀបរយ និង សន្តិសុខសង្គម និងប៉ះពាល់ដល់បូរណភាពរបស់រូបវន្តបុគ្គលដទៃយ៉ាងធ្ងន់ធ្ងរ និងការអភិវឌ្ឍន៍សង្គម ដែលច្បាប់ការពារ។



Scanned with CamScanner

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋាន៖ ក្រោយពីចប់កិច្ចពិភាក្សាដេញដោលនាពេលសវនាការឃើញថា៖ កូនក្ដីរបស់ខ្លួនឈ្មោះ [redacted] ខូច គ្មានចេតនាជួញដូរសារធាតុញៀនទេ គាត់គ្រាន់តែជាអ្នកដឹកជញ្ជូនស៊ីឈ្នួលយកកម្រៃសេវាថ្លៃដឹកជញ្ជូន ដោយសារគាត់គឺជាអ្នករត់ម៉ូតូកង់បី និងមិនដឹងថាក្នុងស្បោងខ្មៅនោះមានគ្រឿងញៀនទេ ហើយកូនក្ដីខ្ញុំបាទមានគ្រួសារនៅក្នុងបន្ទុកត្រូវចិញ្ចឹមបីពាច់ និងមានម្ដាយចាស់ជរា និងមានកូនតូចៗចំនួន៣នាក់ ក្នុងបន្ទុកគ្រួសារត្រូវមើលថែទាំទៀតផង ជាពិសេសដើម្បីទុកឱកាសឱ្យកូនក្ដីខ្ញុំបានកសាងជីវិតជាថ្មី និងបានដឹងពីកំហុសខុសឆ្គងនឹងច្បាប់រដ្ឋ។ ហេតុដូច្នេះ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ ស្នើរសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រាលទោសដល់កូនក្ដីរបស់ខ្លួនផង។ គប្បីតុលាការពិចារណា។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ខូច សុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង គប្បីតុលាការលើកយកមកពិចារណា។

**ហេតុដូច្នេះសម្រេច**

១-ផ្ដន្ទាទោសលើជនជាប់ចោទ៖ ឈ្មោះ [redacted] ខូច ហៅ ជីវ័ន្ត ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ (ដែលមានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ២៦(ម្ភៃប្រាំមួយ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០.០០០.០០០(ហុកសិបលាន)រៀល ពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិក្រាំត្បាល់ ឃុំក្រាំងឈាវ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុតាងរួមមាន៖ ថ្នាំញៀនប្រភេទមេតំហ្វេតាមីន ពណ៌សថ្លា មានទម្ងន់ ៨៥៤,៣៦ ក្រាម និងទូរស័ព្ទពណ៌ប្រផេះ ចំនួន០១គ្រឿង (តាមកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២១) ត្រូវរឹបអូសតាមមាត្រាមាត្រា ៩៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃពុធ ១៣កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ខូច។

បើកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| | | | |
|---|---|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| **ហត្ថលេខានិងត្រា** | **ហត្ថលេខា** | **ហត្ថលេខា** | **ហត្ថលេខានិងត្រា** |

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១៣កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅតាកែវ, ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner